តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia




# ព័ត៌មានថវិកាសម្រាប់ប្រជាពលរដ្ឋ

# ថវិកាជាតិឆ្នាំ២០២៤

## សេចក្ដីប្រកាសអំពី ការទទួលខុសត្រូវ

ឯកសារនេះត្រូវបានរៀបរៀងឡើងតាមរយៈជំនួយហិរញ្ញវត្ថុរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID)  និងការគាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) និងសហភាពអឺរ៉ុប (EU)។ រាល់ខ្លឹមសារនៅក្នុងឯកសារនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយណាមួយឡើយ។

ខែសីហា ឆ្នាំ២០២៤
ដឹកនាំផលិតដោយ អង្គការតម្លាភាពកម្ពុជា ក្រោមកិច្ចសហការ និងពិគ្រោះយោបល់ពីក្រុមការងារថវិកា
ឯកសារនេះស្ថិតនៅក្រោមអាជ្ញាប័ណ្ណនៃការរក្សាសិទ្ធិ CC BY-ND 4.0



## អំពីឯកសារ និងក្រុមការងារ

**ព័ត៌មានថវិកាសម្រាប់ប្រជាពលរដ្ឋ** គឺជាឧបករណ៍សម្រាប់លើកកម្ពស់ចំណេះដឹងផ្នែកថវិកា ដែលត្រូវបានរៀបចំឡើងដើម្បីឱ្យប្រជាពលរដ្ឋភាគច្រើន មានលទ្ធភាពយល់ដឹងអំពីព័ត៌មានថវិកាជាតិដែលមានឥទ្ធិពលលើជីវភាពរបស់ពួកគាត់។ ព័ត៌មានថវិកាសម្រាប់ប្រជាពលរដ្ឋផ្ដល់នូវព័ត៌មានសង្ខេបងាយយល់ដោយរៀបចំទិន្នន័យថវិកាជាតិឱ្យសមស្របទៅតាមបរិបទ  និងប្រើប្រាស់ក្រាហ្វិកសាមញ្ញៗ។  ការរៀបចំឯកសារនេះពុំមានគោលបំណងដើម្បីជំនួសឯកសារផ្លូវការរបស់រដ្ឋាភិបាលឡើយ  ប៉ុន្តែដើម្បីរួមចំណែកក្នុងការជំរុញឱ្យមានកិច្ចពិភាក្សាកាន់តែប្រសើរពីភាគីពាក់ព័ន្ធទៅលើថវិកាជាតិ។

**អង្គការតម្លាភាពកម្ពុជា** គឺជាតំណាងប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិ ដែលមានការិយាល័យកណ្ដាលនៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់។ យើងធ្វើការជាមួយបុគ្គល និងស្ថាប័នគ្រប់កម្រិត ដូចជា រដ្ឋាភិបាល សង្គមស៊ីវិល អាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន ដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព លើកកម្ពស់សុចរិតភាព និងប្រឆាំងអំពើពុករលួយ។

**ក្រុមការងារថវិកា** គឺជាសម្ព័ន្ធអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ដែលធ្វើការរួមគ្នាដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។



## មាតិកា


| មាតិកា | ទំព័រ |
|---|---|
| • ពាក្យគន្លឹះ | ៤ |
| • ចំណូល និងចំណាយថវិការដ្ឋ | ៦ |
| • ចំណាយថវិកាថ្នាក់ជាតិ | ១៥ |
| • ចំណាយថវិកាថ្នាក់ក្រោមជាតិ | ៣២ |
| • សន្និធិបំណុលសាធារណៈ | ៤២ |
| • ប្រភពឯកសារ | ៤៥ |


## ពាក្យគន្លឹះ

| | |
|---|---|
| **ចំណូលចរន្ត** | ចំណូលដែលទទួលបានជាប្រចាំមកពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ **ចំណូលសារពើពន្ធ**សំដៅលើចំណូលបានមកពីពន្ធនិងអាករក្នុងប្រទេស និងពាណិជ្ជកម្មក្រៅប្រទេស ព្រមទាំងចំណូលសារពើពន្ធដទៃទៀត។ ចំណូលសារពើពន្ធមានដូចជាៈ ពន្ធផ្ទាល់ (ពន្ធលើប្រាក់ចំណូល ប្រាក់បៀវត្ស ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ) ពន្ធប្រយោល (អាករលើផលរបរ អាករលើតម្លៃបន្ថែមលើទំនិញនិងសេវា) អាករពិសេសលើទំនិញនិងសេវាមួយចំនួន ពន្ធប៉ាតង់ ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះ) ពន្ធប្រថាប់ត្រា ពន្ធលើអចលនទ្រព្យ ពន្ធនិងអាករលើការនាំចូលនិងការនាំចេញ។ ដោយឡែក **ចំណូលមិនមែនសារពើពន្ធ** គឺជាចំណូលបានមកពីការចាត់ចែង ការធ្វើអាជីវកម្ម និងការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ ផលបានមកពីសម្បទាន កម្រៃបានមកពីសេវាសាធារណៈ ផលពីការពិន័យនិងការដាក់ទណ្ឌកម្ម ការឧបត្ថម្ភអំណោយ ផលហិរញ្ញវត្ថុ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត។ |
| **ចំណូលមូលធន** | ចំណូលដែលមានប្រភពមកពីការវិនិយោគរបស់រដ្ឋ អចលកម្មហិរញ្ញវត្ថុ (ចំណូលពីការសងមកវិញនូវការឱ្យខ្ចីទៅសហគ្រាសសាធារណៈនិងឯកជន) ប្រាក់កម្ចី ជំនួយឥតសំណងរបស់ដៃគូអភិវឌ្ឍន៍ ឬមូលនិធិគាំទ្រ ទាំងក្នុងនិងក្រៅប្រទេស។ |
| **ចំណាយចរន្ត** | មូលនិធិដែលត្រូវបានប្រើប្រាស់ជាប្រចាំដើម្បីទ្រទ្រង់កិច្ចប្រតិបត្តិការផ្នែករដ្ឋបាល។ ចំណាយចរន្តរួមមានៈ **ចំណាយបន្ទុកបុគ្គលិក** (ប្រាក់បៀវត្ស អត្ថប្រយោជន៍ និងចំណាយផ្សេងទៀតសម្រាប់មន្ត្រីរាជការ បុគ្គលិកក្របខ័ណ្ឌនិងមិនមែនក្របខ័ណ្ឌ) និង**ចំណាយក្រៅបន្ទុកបុគ្គលិក** មានដូចជា ការទិញ (សម្ភារការិយាល័យ សម្ភារសម្រាប់ការងារថែទាំនិងជួសជុល អគ្គិសនីនិងទឹក បរិក្ខារថែទាំសុខភាព) ចំណាយលើសេវាកម្ម (ការជួលសេវាអនាម័យ រដ្ឋបាល មធ្យោបាយដឹកជញ្ជូន សេវាថែទាំនិងជួសជុលពីសហគ្រាសឯកជន ការជួលទីតាំងសម្រាប់ការងាររដ្ឋបាល សេវាធានារ៉ាប់រង សោហ៊ុយបេសកកម្ម សេវាទូរសព្ទ ទូរសារ ឬអ៊ិនធឺណិត) បន្ទុកហិរញ្ញវត្ថុ (ការប្រាក់នៃបំណុលក្នុងនិងក្រៅប្រទេស និងបន្ទុកហិរញ្ញវត្ថុផ្សេងទៀត) ចំណាយលើការផ្តល់អត្ថប្រយោជន៍សង្គម (អត្ថប្រយោជន៍សន្តិសុខសង្គម ជំនួយសង្គមដល់ប្រជាពលរដ្ឋ ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គមនិងវប្បធម៌ និងការផ្តល់អត្ថប្រយោជន៍សង្គមផ្សេងទៀត) ការផ្តល់ឧបត្ថម្ភធន និងចំណាយក្រៅបន្ទុកបុគ្គលិកផ្សេងទៀត រួមទាំងចំណាយមិនបានគ្រោងទុកផងដែរ។ |

## ពាក្យគន្លឹះ

| | |
|---|---|
| **ចំណាយមូលធន** | មូលនិធិដែលត្រូវបានប្រើប្រាស់សម្រាប់វិនិយោគក្នុងកិច្ចអភិវឌ្ឍប្រទេសដើម្បីបង្កើនប្រាក់ចំណូលនាពេលខាងមុខ។ វាអាចរួមបញ្ចូលការផ្តល់ថវិកាក្នុងគម្រោងវិនិយោគ ភាពជាដៃគូ និងការរំលោះបំណុល។ ឧទាហរណ៍៖ ការទិញសម្ភារប្រើប្រាស់យូរឆ្នាំ ការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធសាធារណៈរួមមាន ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ អាគាររដ្ឋជាដើម។ |
| **ឱនភាពថវិកា** | ថវិកាដែលខ្វះខាត បន្ទាប់ពីទូទាត់រវាងចំណូលថវិកា និងចំណាយថវិកា។ |
| **សន្និធិបំណុលសាធារណៈ** | ទំហំបំណុលជាក់ស្តែងរបស់រដ្ឋាភិបាលដែលមិនទាន់បានទូទាត់ជូនភាគីម្ចាស់បំណុល។ |
| **មូលបត្ររដ្ឋ** | ប័ណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល។ |
| **អតិរេកថវិកា** | ខ្ទង់ចំណូលដែលនៅសល់ជាក់ស្តែង ក្រោយពេលដែលចំណូលគ្រប់ប្រភេទដែលទទួលបាន ដកចេញនូវចំណាយគ្រប់ប្រភេទដែលបានចំណាយរួច។ |

ប្រភព៖
- សន្ទានុក្រមគតិយុត្ត (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២១)
- ប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងក្រោមជាតិ
- សេចក្តីសង្ខេបនៃព័ត៌មានថវិកាជាតិ (ក្រុមការងារថវិកា ឆ្នាំ២០១៧)







តើគម្រោងចំណូលថវិការដ្ឋ
៣២ ៥០៨ ៩៣៩,៦លានរៀល
បានមកពីប្រភពណាខ្លះ?
ចំណូលថ្នាក់ក្រោមជាតិ
២ ៦១២ ៩៥៩,៦ លានរៀល
៨%
២០២៤
៩២%
ចំណូលថ្នាក់ជាតិ
២៩ ៨៩៥ ៩៨០ លានរៀល
៨៤,៨%
៩,៧%
៥,៥%
ចំណូលសារពើពន្ធ
២ ២១៤ ៧២១ លានរៀល
ចំណូលមិនមែនសារពើពន្ធ
២៥៣ ៤១៣ លានរៀល
មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ
១៤៤ ៨២៥,៦ លានរៀល
ចំណូលមិនមែនសារពើពន្ធ
៣ ០៧៧ ៤១៦ លានរៀល **
១១%
៨៩%
ចំណូលសារពើពន្ធ
២៥ ៧៥៩ ០៦១ លានរៀល *
ចំណូលចរន្ត
២៨ ៨៣៦ ៤៧៧ លានរៀល
៩៦%
៤%
ចំណូលមូលធន
១ ០៥៩ ៥០៣ លានរៀល
ចំណូលមូលធនក្រៅប្រទេស
៦៩៦ ៣៧៧ លានរៀល
(វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ៦២៨ ៧២៧ លានរៀល
មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ៦៧ ៦៥០ លានរៀល)
៦៦%
៣៤%
ចំណូលមូលធនក្នុងប្រទេស
៣៦៣ ១២៦ លានរៀល
* ចំណូលសារពើពន្ធថ្នាក់ជាតិ
២៥ ៧៥៩ ០៦១ លានរៀល
ចំណូលគយ និងរដ្ឋាករ
១១ ១១៧ ៧៩១
លានរៀល
៤៣%
៥៧%
ចំណូលពន្ធដារ
១៤ ៦៤១ ២៧០
លានរៀល
ពន្ធក្នុងប្រទេស
២៣ ២០០ ៧០៨
លានរៀល
៩០%
១០%
ពន្ធលើពាណិជ្ជកម្ម
ក្រៅប្រទេស
២ ៥៥៨ ៣៥៣
លានរៀល
** ចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិ
៣ ០៧៧ ៤១៦ លានរៀល
ចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ
និងចំណូលមិនមែនសារពើពន្ធ
ផ្សេងទៀតថ្នាក់ជាតិ
២ ៧៨៦ ៨១៧
លានរៀល
ចំណូលពាក់ព័ន្ធ
នឹងកាតព្វកិច្ចពី
កាស៊ីណូ ឆ្នោត
និងអាជ្ញាប័ណ្ណ
២៩០ ៥៩៩ លានរៀល
៩%
៩១%

| | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | បម្រែបម្រួល (%) |
|---|---|---|---|
| គម្រោងចំណូលសរុបថវិការដ្ឋ (ឯកតាលានរៀល) | ៣៦ ៧៦៧ ៦៧០ | ៣២ ៥០៨ ៩៣៩,៦ | -១២% |
| ចំណូលថ្នាក់ជាតិ | ៣៤ ១៦៥ ១៦៣ | ២៩ ८៩៥ ៩៨០ | -១២% |
| **ចំណូលចរន្ត** | **២៥ ៥៦៤ ៤២៨** | **២៨ ៨៣៦ ៤៧៧** | **១៣%** |
| ចំណូលសារពើពន្ធ | ២៣ ៤២១ ៩២៤ | ២៥ ៧៥៩ ០៦១ | ១០% |
| ចំណូលមិនមែនសារពើពន្ធ | ២ ១៤២ ៥០៤ | ៣ ០៧៧ ៤១៦ | ៤៤% |
| **ចំណូលមូលធន** | **៨ ៦០០ ៧៣៥** | **១ ០៥៩ ៥០៣** | **-៨៨%** |
| ចំណូលមូលធនក្នុងប្រទេស | ១ ១៤៤ ៨១២ | ៣៦៣ ១២៦ | -៦៨% |
| ចំណូលមូលធនក្រៅប្រទេស | ៧ ៤៥៥ ៩២៣ | ៦៩៦ ៣៧៧ | -៩១% |
| មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ១ ២៨២ ៥០៨ | ៦៧ ៦៥០ | -៩៥% |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៦ ១៧៣ ៤១៥ | ៦២៨ ៧២៧ | -៩០% |
| ចំណូលថ្នាក់ក្រោមជាតិ | ២ ៦០២ ៥០៧ | ២ ៦១២ ៩៦០ | 0% |
| ចំណូលសារពើពន្ធ | ២ ១៧២ ៣៥០ | ២ ២១៤ ៧២១ | ២% |
| ចំណូលមិនមែនសារពើពន្ធ | ២៩៥ ២៧៦ | ២៥៣ ៤១៣ | -១៤% |
| មូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១៣៤ ៨៨១ | ១៤៤ ៨២៦ | ៧% |



គម្រោងចំណាយសរុបថវិការដ្ឋក្នុងឆ្នាំ២០២៤ មានចំនួន **៣៧ ១១០ ៤០៣ លានរៀល** ដែល**ថយចុះប្រមាណ ៥,៣%** ធៀបនឹងគម្រោងចំណាយសរុបឆ្នាំ២០២៣។ ក្នុងឆ្នាំ២០២៤ អតិរេកចរន្តមានចំនួន ៥ ០៣០ ៦៣៩  លានរៀល ឬកើនឡើងប្រមាណ ៦%ធៀបនឹងឆ្នាំមុន។ ឱនភាពថវិការដ្ឋឆ្នាំ២០២៤មានអត្រា **១២%**។



ចំណាយសរុបថវិការដ្ឋ ឆ្នាំ២០២៤ (គម្រោង)

ចំណូលថវិការដ្ឋ ឆ្នាំ២០២៤ (គម្រោង)

## ឱនភាពថវិការដ្ឋ

ឱភាពថវិការដ្ឋឆ្នាំ២០២៤មានចំនួន **៤ ៦០១ ៤៦៤ លានរៀល** (១២%)។ រដ្ឋាភិបាលគ្រោងបំពេញបន្ថែមឱភាពនេះដោយៈ

- ហិរញ្ញប្បទានក្រៅប្រទេស **៣ ៤៦៤ ៤៦៤ លានរៀល**
- មូលនិធិទ្រទ្រង់ថវិកាដោយដៃគូអភិវឌ្ឍ **៦៩៧ ០០០ លានរៀល**
- ការបោះផ្សាយលក់មូលបត្ររដ្ឋ **៤៤០ ០០០ លានរៀល**


តើគម្រោងចំណាយសរុបថវិការដ្ឋ
៣៧ ១១០ ៤០៣ លានរៀល
ត្រូវបានបែងចែកយ៉ាងដូចម្តេចខ្លះ?
២០២៤
៧០%
៣០%
ចំណាយចរន្ត
២៥ ៨៨៣ ៧៩៧ លានរៀល
ចំណាយបន្ទុកបុគ្គលិក
១១ ១៨៨ ៣៦១ លានរៀល
៤៣%
៥៧%
ចំណាយក្រៅបន្ទុកបុគ្គលិក
១៤ ៦៩៥ ៤៣៦ លានរៀល
ចំណាយបន្ទុកបុគ្គលិកថ្នាក់ជាតិ
១០ ២៥៤ ៩៦៧ លានរៀល
៩២%
៨%
ចំណាយបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិ
៩៣៣ ៣៩៤ លានរៀល
ចំណាយក្រៅបន្ទុកបុគ្គលិកថ្នាក់ជាតិ
១៣ ៥៥០ ៨៧១ លានរៀល
ចំណាយក្រៅបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិ
២ ៨៦៣ ៤៧៦ លានរៀល *
* ថវិកាចំនួន ១ ៧១៨ ៩១១ លានរៀល នៅក្នុងចំណាយក្រៅបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិ គឺជាឧបត្ថម្ភធនពីចំណាយថវិកាថ្នាក់ជាតិ។
ចំណាយមូលធន
១១ ២២៦ ៦០៦ លានរៀល
៤៥%
៥៥%
វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
៥ ០១៨ ៧៣០ លានរៀល
៨៩%
ថ្នាក់ជាតិ
៤ ៤៨៣ ៧៣០ លានរៀល
១១%
ថ្នាក់ក្រោមជាតិ
៥៣៥ ០០០ លានរៀល
វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស
៦ ២០៧ ៨៧៦ លានរៀល

| | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | បម្រែបម្រួល (%) |
|---|---|---|---|
| គម្រោងចំណាយសរុបថវិការដ្ឋ (ឯកតាលានរៀល) | ៣៩ ២០៦ ២០៥ | ៣៧ ១១០ ៤០៣ | -៥,៣% |
| ចំណាយចរន្តថវិការដ្ឋ | ២២ ៩២៨ ៩៣២ | ២៥ ៨៨៣ ៧៩៧ | ១២,៩% |
| ចំណាយបន្ទុកបុគ្គលិក<br>ចំណាយបន្ទុកបុគ្គលិកថ្នាក់ជាតិ<br>ចំណាយបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិ | ១០ ៤៣៥ ១១១<br>៩ ៥៥៥ ១៩៧<br>៨៧៩ ៩១៤ | ១១ ១៨៨ ៣៦១<br>១០ ២៥៤ ៩៦៧<br>៩៣៣ ៣៩៤ | ៧,២%<br>៧,៣%<br>៦,១% |
| ចំណាយក្រៅបន្ទុកបុគ្គលិក<br>ចំណាយក្រៅបន្ទុកបុគ្គលិកថ្នាក់ជាតិ<br>ចំណាយក្រៅបន្ទុកបុគ្គលិកថ្នាក់ក្រោមជាតិ* | ១២ ៤៩៣ ៨២២<br>១១ ២៨៤ ២២៩<br>២ ៦៦៨ ៨៨៣ | ១៤ ៦៩៥ ៤៣៦<br>១៣ ៥៥០ ៨៧១<br>២ ៨៦៣ ៤៧៦ | ១៧,៦%<br>២០,១%<br>៧,៣% |
| *ឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិសម្រាប់ ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ | ១ ៤៥៩ ២៩០ | ១ ៧១៨ ៩១១ | ១៧,៨% |
| ចំណាយមូលធនថវិការដ្ឋ | ១៦ ២៧៧ ២៧៣ | ១១ ២២៦ ៦០៦ | -៣១,០% |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស<br>ថ្នាក់ជាតិ<br>ថ្នាក់ក្រោមជាតិ | ៨ ២៤៣ ៩៧១<br>៧ ៧៣០ ៩៧១<br>៥១៣ ០០០ | ៥ ០១៨ ៧៣០<br>៤ ៤៨៣ ៧៣០<br>៥៣៥ ០០០ | -៣៩,១%<br>-៤២.០%<br>៤.៣% |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៦ ១៧៣ ៤១៥ | ៦ ២០៧ ៨៧៦ | ០,៦% |
| ការទូទាត់ការខ្ចី | ១ ៨៥៩ ៨៨៧ | គ្មានព័ត៌មាន | គ្មានព័ត៌មាន |

ចំណាំ៖ ការទូទាត់ការខ្ចីមិនត្រូវបានគ្រោងជាឥណទានចំណាយក្នុងឆ្នាំ២០២៤











ក្នុងឆ្នាំ២០២៤ គម្រោងចំណាយថ្នាក់ជាតិ ថយចុះ ៥,៨% បើធៀបនឹងឆ្នាំ២០២៣។


២០ ២៤
៦៩%
៣១%
ចំណាយចរន្ត
២៣ ៨០៥ ៨៣៨ លានរៀល
ចំណាយបន្ទុកបុគ្គលិក
១០ ២៥៤ ៩៦៧ លានរៀល
៤៣%
៥៧%
ចំណាយក្រៅបន្ទុកបុគ្គលិក
១៣ ៥៥០ ៨៧១ លានរៀល
ចំណាយមូលធន
១០ ៦៩១ ៦០៦ លានរៀល
ដោយថវិកាថ្នាក់ជាតិ
៣ ៧៥៣ ៥២០ លានរៀល
៨៤%
១៦%
ដោយមូលនិធិដៃគូអភិវឌ្ឍ
៧៣០ ២១០ លានរៀល
វិនិយោគសាធារណៈដោយ
ហិរញ្ញប្បទានក្នុងប្រទេស
៤ ៤៨៣ ៧៣០ លានរៀល
៤២%
៥៨%
វិនិយោគសាធារណៈដោយ
ហិរញ្ញប្បទានក្រៅប្រទេស
៦ ២០៧ ៨៧៦ លានរៀល
តើគម្រោងចំណាយថ្នាក់ជាតិ
៣៤ ៤៩៧ ៤៤៤ លានរៀល
ត្រូវបានបែងចែកយ៉ាងដូចម្ដេចខ្លះ?

| | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | បម្រែបម្រួល (%) |
|---|---|---|---|
| គម្រោងចំណាយសរុបថ្នាក់ជាតិ (ឯកតាលានរៀល) | ៣៦ ៦០៣ ៦៩៨ | ៣៤ ៤៩៧ ៤៤៤ | -៥,៨% |
| ចំណាយចរន្ត | ២០ ៨៣៩ ៤២៥ | ២៣ ៨០៥ ៨៣៨ | ១៤,២% |
| ចំណាយបន្ទុកបុគ្គលិក | ៩ ៥៥៥ ១៩៧ | ១០ ២៥៤ ៩៦៧ | ៧,៣% |
| ចំណាយក្រៅបន្ទុកបុគ្គលិក | ១១ ២៨៤ ២២៩ | ១៣ ៥៥០ ៨៧១ | ២០,១% |
| ចំណាយមូលធន | ១៥ ៧៦៤ ២៧៣ | ១០ ៦៩១ ៦០៦ | -៣២,២% |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ៧ ៧៣០ ៩៧១ | ៤ ៤៨៣ ៧៣០ | -៤២,០% |
| ដោយថវិកាថ្នាក់ជាតិ | ៦ ៤៤៨ ៤៦៣ | ៣ ៧៥៣ ៥២០ | -៤១,៨% |
| គម្រោងវិនិយោគផ្ទាល់ | ៥ ៧១៩ ១៥៩ | ២ ៩៨៧ ៧៥១ | -៤៧,៨% |
| បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស | ៧២៩ ៣០៤ | ៧៦៥ ៧៦៩ | ៥,០% |
| ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ១ ២៨២ ៥០៨ | ៧៣០ ២១០ | -៤៣,១% |
| វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៦ ១៧៣ ៤១៥ | ៦ ២០៧ ៨៧៦ | ០,៦% |
| ការទូទាត់ការខ្ចី | ១ ៨៥៩ ៨៨៧ | គ្មានព័ត៌មាន | គ្មានព័ត៌មាន |



## តើគម្រោងចំណាយថវិកាថ្នាក់ជាតិត្រូវបានបែងចែកតាមវិស័យនីមួយៗយ៉ាងដូចម្តេចនៅក្នុងឆ្នាំ២០២៤?



# តើគម្រោងចំណាយថវិកាថ្នាក់ជាតិតាមវិស័យមានការប្រែប្រួលដូចម្ដេចខ្លះ រវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤?




ចំណាំ៖ ចំណាយមិនបានគ្រោងទុក ត្រូវបានធ្វើចំណាត់ថ្នាក់ថវិកា ជាជំពូកថ្មី ក្នុងឆ្នាំ២០២៤។



## វិស័យរដ្ឋបាលទូទៅ

ព្រះបរមរាជវាំង
រដ្ឋសភា
ព្រឹទ្ធសភា
ក្រុមប្រឹក្សាធម្មនុញ្ញ
ទីស្ដីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រសួងផែនការ
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អាជ្ញាធរសវនកម្មជាតិ
ស្ថាប័នប្រឆាំងអំពើពុករលួយ
ក្រសួងមុខងារសាធារណៈ

## វិស័យការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

ក្រសួងការពារជាតិ
ក្រសួងមហាផ្ទៃ
ក្រសួងយុត្តិធម៌

## វិស័យសង្គមកិច្ច

ក្រសួងព័ត៌មាន
ក្រសួងសុខាភិបាល
ក្រសួងអប់រំ យុវជន និងកីឡា
ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
ក្រសួងបរិស្ថាន
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
ក្រសួងធម្មការ និងសាសនា
ក្រសួងកិច្ចការនារី
ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

## វិស័យសេដ្ឋកិច្ច

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
ក្រសួងរ៉ែ និងថាមពល
ក្រសួងពាណិជ្ជកម្ម
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ក្រសួងអភិវឌ្ឍន៍ជនបទ
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
ក្រសួងសាធារណការ និងដឹកជញ្ជូន
ក្រសួងទេសចរណ៍
ក្រសួងធនធានទឹក និងឧតុនិយម
ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

# តើថវិកាថ្នាក់ជាតិ ត្រូវបានបែងចែក តាមក្រសួងនីមួយៗ ដូចម្ដេចខ្លះ ក្នុងឆ្នាំ២០២៤?






១ ក្រសួងទេសចរណ៍
១១៤ ៤៨៨,៥ លានរៀល (០,៣៣%)

២ ក្រសួងផែនការ
៩២ ៥៦៧ លានរៀល (០,២៧%)

៣ ក្រសួងព្រះបរមរាជវាំង
៩២ ៤៤៣ លានរៀល (០,២៧%)

៤ ក្រសួងព័ត៌មាន
៩០ ៨០៨ លានរៀល (០,២៦%)

៥ ព្រឹទ្ធសភា
៨៦ ០០៣ លានរៀល (០,២៥%)

៦ ក្រសួងធម្មការ និងសាសនា
៧៤ ២៧៨ លានរៀល (០,២២%)

៧ ក្រសួងមុខងារសាធារណៈ
៦៩ ៨៨៦ លានរៀល (០,២០%)

៨ រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល
៥៣ ៣៣២ លានរៀល (០,១៥%)

៩ ស្ថាប័នប្រឆាំងអំពើពុករលួយ
៥២ ៥៥៩ លានរៀល (០,១៥%)

១០ ក្រសួងកិច្ចការនារី
៥១ ០៦៧ លានរៀល (០,១៥%)

១១ ក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច
៤៧ ៤៥៥ លានរៀល (០,១៤%)

១២ ក្រុមប្រឹក្សាធម្មនុញ្ញ
១៦ ០០៥ លានរៀល (០,០៥%)

១៣ អាជ្ញាធរសវនកម្មជាតិ
១៥ ៣១៣ លានរៀល (០,០៤%)

១៤ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
១៥ ២៣៤ លានរៀល (០,០៤%)






# តើគម្រោងចំណាយតាមក្រសួងធំៗមានការប្រែប្រួលដូចម្ដេចខ្លះ រវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤?

*ថវិកាក្រសួងអប់រំ យុវជន និងកីឡា ធ្លាក់ចុះប្រមាណ៣៦% ធៀបនឹងឆ្នាំ២០២៣ ដោយសារចាប់ពីឆ្នាំ២០២៤នេះ កញ្ចប់ថវិកាមុខងារអប់រំ (អប់រំក្រៅប្រព័ន្ធ កុមារតូច និងបឋមសិក្សា) ត្រូវបានប្ដូរទីតាំងវិភាជពីកញ្ចប់ថវិកាមន្ទីររាជធានីខេត្ត នៃថវិកាថ្នាក់ជាតិ ទៅកញ្ចប់ថវិកានៃរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ នៃថវិកាថ្នាក់ក្រោមជាតិ។




ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃប្រទេសកម្ពុជា។ រូបភាពពីទំព័រហ្វេសប៊ុករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## គម្រោងចំណាយថ្នាក់ជាតិរបស់ក្រសួងនីមួយៗតាមប្រភេទចំណាយ ក្នុងឆ្នាំ២០២៤(%)




## គម្រោងចំណាយថ្នាក់ជាតិរបស់ក្រសួងនីមួយៗតាមប្រភេទចំណាយ ក្នុងឆ្នាំ២០២៤(%)



| "គម្រោងចំណាយថវិកាថ្នាក់ជាតិ តាមក្រសួង (ឯកតាលានរៀល)" | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | បម្រែបម្រួល % |
|---|---|---|---|
| ក្រសួងរ៉ែ និងថាមពល | ៤៦៥ ៨១៩,៣ | ៦៣៥,២៣៩,០ | ៣៦% |
| ក្រសួងផែនការ | ៨១ ៨៣៣,០ | ៩២,៥៦៧.,០ | ១៣% |
| ក្រសួងសុខាភិបាល | ២ ០៣៤ ៥៥២,៦ | ១ ៧៨១ ១៤៣,០ | -១២% |
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ | ៥៨០ ៩២២,០ | ៣៩៩ ២៥៧,០ | -៣១% |
| ចំណាយមិនទាន់បែងចែកមានមុខសញ្ញា | ១១ ៤០៩ ៥៨០,៤ | ៨ ៣៣៥ ៣០៤,៧ | -២៧% |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ ៤៦៨ ៨៥៥,០ | ២ ៣១៤ ៦៤៥,០ | ៥៨% |
| ទីស្ដីការគណៈរដ្ឋមន្ត្រី | ៤៨២ ០៥៩,០ | ៥២៦ ៦៤៨,០ | ៩% |
| ព្រឹទ្ធសភា | ៧៤ ០២១,០ | ៨៦ ០០៣,០ | ១៦% |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១៦៨ ១១៥,០ | ១៩៣ ០៥៦,០ | ១៥% |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១៧៥ ៣៧៨,០ | ១៨៣ ៥៣៣,០ | ៥% |
| ក្រសួងធម្មការ និងសាសនា | ៦៩ ៣៥៣,០ | ៧៤ ២៧៨,០ | ៧% |
| ក្រសួងកិច្ចការនារី | ៤៦ ២៤៣,០ | ៥១ ០៦៧,០ | ១០% |
| ក្រសួងសាធារណការ និងដឹកជញ្ជូន | ២ ៧២១ ០៤០,០ | ២ ៨៥១ ៣០១,៥ | ៥% |
| ក្រសួងការពារជាតិ | ២ ៧៤៥ ៥៧៥,០ | ២ ៩៣៤ ៥១៨,០ | ៧% |
| ក្រសួងមហាផ្ទៃ | ២ ២៧៤ ០៩៨,០ | ២ ៣៩០ ៤១៣,០ | ៥% |
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ៣០០ ២០៩,០ | ១៣៥ ៧៨៥,០ | -៥៥% |
| រដ្ឋសភា | ១៩១ ១១០,០ | ២១៩ ៣១៣,០ | ១៥% |
| ក្រសួងអប់រំ យុវជន និងកីឡា | ៣ ៥៧៩ ៦៦៣,៦ | ២ ៣០១ ៥០៣,៣ | -៣៦% |
| ក្រសួងព្រះបរមរាជវាំង | ៨៥ ៩០៣,០ | ៩២ ៤៤៣,០ | ៨% |
| ក្រសួងធនធានទឹក និងឧតុនិយម | ៧៦៨ ៨៣៦,០ | ៩៩៧ ០៩៤,០ | ៣០% |

| "គម្រោងចំណាយថវិកាថ្នាក់ជាតិ តាមក្រសួង (ឯកតាលានរៀល)" | ឆ្នាំ២០២៣ | ឆ្នាំ២០២៤ | បម្រែបម្រួល % |
|---|---|---|---|
| អាជ្ញាធរសវនកម្មជាតិ | ១៣ ८៣៧,០ | ១៥ ៣១៣,០ | ១១% |
| ក្រសួងទេសចរណ៍ | ១១២ ០៦៣,៣ | ១១៤ ៤៨៨,៥ | ២% |
| ក្រសួងយុត្តិធម៌ | ១៩៥ ៨៧៣,០ | ២១៥ ៨០៥,០ | ១០% |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១២ ៩៨៥,០ | ១៥ ២៣៤,០ | ១៧% |
| ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ៤៥ ០១១,០ | ៤៧ ៩៥៥,០ | ៦% |
| ក្រសួងព័ត៌មាន | ៩៣ ២៣៥,៦ | ៩០ ៨០៨,០ | -៣% |
| ស្ថាប័នប្រឆាំងអំពើពុករលួយ | ៤៨ ៤៤២,០ | ៥២ ៥៤៩,០ | ៨% |
| ក្រសួងអភិវឌ្ឍន៍ជនបទ | ១ ០២៣ ៧៧៤,០ | ១ ២៩២ ៥២១,០ | ២៦% |
| ក្រសួងបរិស្ថាន | ១៤១ ៩៧២,០ | ១៧៨ ២៤៦,០ | ២៦% |
| ក្រុមប្រឹក្សាធម្មនុញ្ញ | ១៥ ០២៦,០ | ១៦ ០០៥,០ | ៧% |
| ក្រសួងមុខងារសាធារណៈ | ៦៦ ២៩៨,០ | ៦៩ ៨៨៦,០ | ៥% |
| ក្រសួងពាណិជ្ជកម្ម | ៣២១ ៧៣៣,០ | ១៩៣ ៣៥១,០ | -៤០% |
| រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ៥៣ ៩០៣,០ | ៥៣ ៣៣២,០ | -១% |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣៨៣ ៩៥០,២ | ៥៣៧ ៤៣៦,០ | ៤០% |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៦៥០ ២៤០,៦ | ៦៥៧ ៨១៣,០ | ១% |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១៩៨ ១៤២,០ | ២០០ ២៩៥,០ | ១% |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៣៤៧ ៧២១,៤ | ៣៣៥ ៧២១,០ | -៣% |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៣ ១៥៦ ៣២៥,០ | ១ ៣៦១ ៧៦៧,០ | -៥៧% |


100000
50000
20000
10000
5000
2000
1000


ចំណាយថ្នាក់
ក្រោមជាតិ

## គម្រោងចំណាយថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០២៣ - ២០២៤ (លានរៀល)




គម្រោងចំណាយថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០២៤
**កើនឡើង ៣៧,៨%** បើធៀបនឹងឆ្នាំ២០២៣។






តើគម្រោងចំណាយ**ថវិកាថ្នាក់ក្រោមជាតិ**
៦ ៩៦៩ ១៥៨ លានរៀល
ត្រូវបានបែងចែកយ៉ាងដូចម្តេចខ្លះ?

ចំណាយរដ្ឋបាលក្រុង-ស្រុក
២ ២៥៥ ២៨៤,៥ លានរៀល

ចំណាយរដ្ឋបាលឃុំ-សង្កាត់
១ ១១៥០ ៣៩៩,០ លានរៀល




ចំណាយរដ្ឋបាលរាជធានី-ខេត្ត
៣ ៥៦៣ ៤៧៤,៨ លានរៀល

## តើគម្រោងចំណាយថវិកាថ្នាក់ក្រោមជាតិឆ្នាំ២០២៤ ត្រូវបានបែងចែកតាមកម្រិតរដ្ឋបាលយ៉ាងដូចម្តេចខ្លះ?






ចំណាយមូលធន
៥៣៥ ០០០,០ លានរៀល




ចំណាយចរន្ត
៣ ០២៨ ៤៧៤,៨ លានរៀល

## ចំណាយរដ្ឋបាលរាជធានី-ខេត្ត

# គម្រោងចំណាយថវិកាបែងចែកតាម រដ្ឋបាលរាជធានី-ខេត្ត (ឯកតាលានរៀល)

## ច្បាប់ថវិកាឆ្នាំ២០២៤





ភ្នំពេញ៖ ៨៩៧ ៩២១
- ចំណាយចរន្ត៖ ៧៧៧ ១៦២
- ចំណាយមូលធន៖ ១២០ ៧៥៩



កណ្ដាល៖ ១៣២ ៦៨៣
- ចំណាយចរន្ត៖ ១២៥ ៦៨៣
- ចំណាយមូលធន៖ ៧ ០០០



សៀមរាប៖ ១១០ ១១៦
- ចំណាយចរន្ត៖ ១០៥ ១៧៦
- ចំណាយមូលធន៖ ៤ ៩៤០



ព្រះសីហនុ៖ ៩៩ ១៦២
- ចំណាយចរន្ត៖ ៩៨ ០៥៧
- ចំណាយមូលធន៖ ១ ១០៥



បាត់ដំបង៖ ៩៩ ៦៤៣
- ចំណាយចរន្ត៖ ៩៧ ៦៦៣
- ចំណាយមូលធន៖ ១ ៩៨០



បន្ទាយមានជ័យ៖ ៨៣ ៨៤០
- ចំណាយចរន្ត៖ ៧៤ ៤២៧
- ចំណាយមូលធន៖ ៩ ៤១៣



កំពង់ចាម៖ ៩៣ ៤៨៨,៨
- ចំណាយចរន្ត៖ ៩០ ១៣៨,៨
- ចំណាយមូលធន៖ ៣ ៣៥០



តាកែវ៖ ៨៥ ៩៨៤
- ចំណាយចរន្ត៖ ៨៥ ២៥៤
- ចំណាយមូលធន៖ ៧៣០



ព្រៃវែង៖ ៩៣ ៣៦៣
- ចំណាយចរន្ត៖ ៨៦ ៣៦៣
- ចំណាយមូលធន៖ ៧ ០០០



កំពង់ស្ពឺ៖ ៨៨ ៤៨៤
- ចំណាយចរន្ត៖ ៦៨ ០៦៤
- ចំណាយមូលធន៖ ២០ ៤២០



ត្បូងឃ្មុំ៖ ៨៤ ២០៨
- ចំណាយចរន្ត៖ ៧៨ ៨៤៦
- ចំណាយមូលធន៖ ៥ ៣៦២



កំពត៖ ៧៤ ២៨៨
- ចំណាយចរន្ត៖ ៦៧ ៣៨៨
- ចំណាយមូលធន៖ ៦ ៩០០



ស្វាយរៀង៖ ៦១ ០១៤
- ចំណាយចរន្ត៖ ៥៥ ០១៤
- ចំណាយមូលធន៖ ៦ ០០០



កំពង់ធំ៖ ៥៥ ២៣៥
- ចំណាយចរន្ត៖ ៥០ ៨៦០
- ចំណាយមូលធន៖ ៤ ៣៧៥



ពោធិ៍សាត់៖ ៥៣ ៦៦៤
- ចំណាយចរន្ត៖ ៥០ ៩១៦
- ចំណាយមូលធន៖ ២ ៧៤៨



កំពង់ឆ្នាំង៖ ៥៧ ១៥៩
- ចំណាយចរន្ត៖ ៥៦ ២០២
- ចំណាយមូលធន៖ ៩៥៧



ក្រចេះ៖ ៤៩ ២៥៩
- ចំណាយចរន្ត៖ ៤៩ ២៥៩
- ចំណាយមូលធន៖ ០



ឧត្តរមានជ័យ៖ ៤២ ១៩៧
- ចំណាយចរន្ត៖ ៤១ ៦២៧
- ចំណាយមូលធន៖ ៥៧០



កោះកុង៖ ៤០ ៨១៦
- ចំណាយចរន្ត៖ ៣៩ ០៧៦
- ចំណាយមូលធន៖ ១ ៧៤០



មណ្ឌលគិរី៖ ៣៨ ៦៤៧
- ចំណាយចរន្ត៖ ៣៧ ៨៣៥
- ចំណាយមូលធន៖ ៨១២



រតនគិរី៖ ៤០ ០៤៦
- ចំណាយចរន្ត៖ ៣៣ ០៨៣
- ចំណាយមូលធន៖ ៦ ៩៦៣



ព្រះវិហារ៖ ៣៨ ១១៤
- ចំណាយចរន្ត៖ ២៩ ៦២៤
- ចំណាយមូលធន៖ ៨ ៤៩០



ស្ទឹងត្រែង៖ ៣៥ ៣៤២
- ចំណាយចរន្ត៖ ២៧ ៣៤២
- ចំណាយមូលធន៖ ៨ ០០០



កែប៖ ២៧ ០៧៥
- ចំណាយចរន្ត៖ ២១ ០៧៥
- ចំណាយមូលធន៖ ៦ ០០០



ប៉ៃលិន៖ ២៧ ៨៩២
- ចំណាយចរន្ត៖ ២៧ ៨៩២
- ចំណាយមូលធន៖ ០

| ចំណាយបែងចែកតាមរដ្ឋបាលរាជធានី-ខេត្ត (ឯកតាលានរៀល) | ឆ្នាំ២០២៤ (គម្រោង) | គិតជា % |
|---|---|---|
| ស្ទឹងត្រែង | ៣៥ ៣៤២,០ | ១% |
| ប៉ៃលិន | ២៧ ៨៩២,០ | ១% |
| ព្រះវិហារ | ៣៨ ១១៤,០ | ១% |
| ក្រចេះ | ៤៩ ២៥៩,០ | ១% |
| កោះកុង | ៤០ ៨១៦,០ | ១% |
| កំពង់ចាម | ៩៣ ៤៨៩,០ | ៣% |
| កំពត | ៧៤ ២៨៨,០ | ២% |
| ព្រៃវែង | ៩៣ ៣៦៣,០ | ៣% |
| រតនគិរី | ៤០ ០៤៦,០ | ១% |
| ពោធិ៍សាត់ | ៥៣ ៦៦៤,០ | ២% |
| កំពង់ឆ្នាំង | ៥៧ ១៥៩,០ | ២% |
| បន្ទាយមានជ័យ | ៨៣ ៨៤០,០ | ២% |
| ត្បូងឃ្មុំ | ៨៤ ២០៨,០ | ២% |
| តាកែវ | ៨៥ ៩៨៤,០ | ២% |
| ព្រះសីហនុ | ៩៩ ១៦២,០ | ៣% |
| កំពង់ស្ពឺ | ៨៨ ៤៨៤,០ | ២% |
| ឧត្ដរមានជ័យ | ៤២ ១៩៧,០ | ១% |
| ស្វាយរៀង | ៦១ ០១៤,០ | ២% |
| បាត់ដំបង | ៩៩ ៦៤៣,០ | ៣% |
| សៀមរាប | ១១០ ១១៦,០ | ៣% |
| កំពង់ធំ | ៥៥ ២៣៥,០ | ២% |
| កណ្ដាល | ១៣២ ៦៨៣,០ | ៤% |
| រាជធានីភ្នំពេញ | ៨៩៧ ៩២១,០ | ២៥% |
| កែប | ២៧ ០៧៥,០ | ១% |
| មណ្ឌលគិរី | ៣៨ ៦៤៧,០ | ១% |
| ឧបត្ថម្ភធនពីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិ | ១២៤ ៤៨៦,០ | ៣% |
| ឧបត្ថម្ភធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ | ៩២៩ ៣៥០,០ | ២៦% |
| **សរុប** | **៣ ៥៦៣ ៤៧៥,០** | |



## ចំណាយរដ្ឋបាលក្រុង-ស្រុក

**ចំណាំ៖**

ក្នុងឆ្នាំ២០២៤នេះ គម្រោងចំណាយថវិការដ្ឋបាលក្រុង ស្រុក កើនឡើងខ្លាំងធៀបនឹងឆ្នាំមុនៗ បណ្ដាលមកពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៃ ២៥ រាជធានីខេត្ត ត្រូវបានប្រគល់ និងប្រតិភូកម្មមុខងារ និងធនធានហិរញ្ញវត្ថុ សម្រាប់ផ្ដល់សេវាសាធារណៈនៃមុខងារ អប់រំ០៣កម្រិត(អប់រំក្រៅប្រព័ន្ធ កុមារតូច និងបឋមសិក្សា)។ កាលពីឆ្នាំ២០២១ ដល់២០២៣ ការប្រគល់ និងប្រតិភូកម្មមុខងារ និងធនធាននេះត្រូវបានអនុវត្តចំពោះតែរដ្ឋបាលក្នុងស្រុកទាំង១៤ នៃខេត្តបាត់ដំបងតែប៉ុណ្ណោះ។








ចំណាយរដ្ឋបាលឃុំ-សង្កាត់



# សន្និធិបំណុលសាធារណៈក្រៅប្រទេស គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤
## សរុប ១១ ០០០,០១ លានដុល្លារអាមេរិក

(ឯកតាលានដុល្លារអាមេរិក)

ក្នុងឆ្នាំ២០២៣ រដ្ឋាភិបាលបានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍ សរុបចំនួន **៤៩៥,២៧ លានដុល្លារអាមេរិក**
ក្នុងនោះ ការទូទាត់ប្រាក់ដើមចំនួន ៣៧៩,៦៧ លានដុល្លារអាមេរិក និង ការទូទាត់ការប្រាក់និងកម្រៃផ្សេងៗចំនួន ១១៥,៦០ លានដុល្លារអាមេរិក។









## ប្រភពឯកសារ

ការស្រាវជ្រាវ និងរៀបរៀងឯកសារព័ត៌មានថវិកាសម្រាប់ប្រជាពលរដ្ឋនេះ ត្រូវបានពឹងផ្អែកលើប្រភពឯកសារផ្លូវការដូចខាងក្រោម៖

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ (ព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣)
- ថវិកាសង្ខេបឆ្នាំ២០២៤ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៤)
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ (ព្រះរាជក្រមលេខ នស/រកម/១២២២/០១២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២)
- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ (ព្រះរាជក្រមលេខ នស/រកម/១២២៣/០២៣ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣)
- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ (ព្រះរាជក្រមលេខ នស/រកម/១២២២/០១៤ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២)
- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ (ព្រះរាជក្រមលេខ នស/រកម/១២២១/០២០ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១)
- ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា លេខ២២ (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០២៤)។

ផលិតដោយ៖

អង្គការតម្លាភាពកម្ពុជា

ផ្ទះលេខ១៣ ផ្លូវលេខ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរសព្ទ៖ (+៨៥៥) ២៣ ៨៨៣ ៦៨១ / (+៨៥៥) ២៣ ៨៨៣ ៦៨២
គេហទំព័រ៖ www.ticambodia.org
គេហទំព័រនៅការិយាល័យកណ្ដាល៖ www.transparency.org

សហការផលិតដោយ៖ ក្រុមការងារថវិកា